ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.១៥៦.....សហវ.....ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុ មានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សាគណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលដែលបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការរៀបចំថវិកា និងការអនុវត្តថវិកា ក្នុងក្របខណ្ឌធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តនៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដោយមានមន្ទីរសុខាភិបាល និងទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលជាអង្គភាពថវិកា និងអង្គភាពដទៃទៀតក្រោមឱវាទមន្ទីរសុខាភិបាលជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ក្នុងការអនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលដែលបានប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

## ជំពូកទី ២

## សិទ្ធិអំណាច ការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងការគ្រប់គ្រងថវិកា

**ប្រការ ៤.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាលើវិស័យសុខាភិបាល។

ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផលចំពោះរដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងក្នុងក្របខណ្ឌនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់ឱ្យស្របតាមគោលនយោបាយសុខាភិបាលជាតិ ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ មគ្គុទ្ទេសក៍ណែនាំស្តីពីការប្រតិបត្តិគ្លីនិក ពិធីសារនៃការពិនិត្យព្យាបាល ស្តង់ដាគុណភាព និងបទដ្ឋានបច្ចេកទេសនានាដែលបានកំណត់ និងត្រូវមានគណនេយ្យភាពចំពោះប្រជាជនក្នុងការផ្តល់សេវាសុខាភិបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផលចំពោះក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ លើការរៀបចំនិងអនុវត្តថវិកា និងចង្អោមសកម្មភាពការងាររបស់មន្ទីរសុខាភិបាល និងអង្គភាពក្រោមឱវាទក្នុងការគ្រប់គ្រង ការគាំទ្រផ្នែកបច្ចេកទេស និងតាមដានត្រួតពិនិត្យលើការផ្តល់សេវារបស់មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ។

ប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផល ចំពោះប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត។

ប្រធានមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ប្រធានមណ្ឌលសុខភាព និងប្រធានប៉ុស្តិ៍សុខភាពត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផល ចំពោះប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ។

**ប្រការ ៥.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ជាសេនាធិការ ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តសាមី។

នៅក្នុងដំណាក់កាលនៃការរៀបចំថវិកា ដោយផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ និងក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវដឹកនាំ និងណែនាំមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ឱ្យរៀបចំគម្រោងថវិកាប្រចាំឆ្នាំស្របតាមលក្ខខណ្ឌនានា និងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន និងស្របតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័ត មុននឹងបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទៅក្រសួងសុខាភិបាល ដើម្បីពិនិត្យការផ្សារភ្ជាប់គម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត ជាមួយនឹងគម្រោងថវិការបស់ក្រសួងសុខាភិបាល។

នៅក្នុងដំណាក់កាលនៃការអនុវត្តថវិកា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត គឺជាអាណាប័កដើម-ខ្សែនៃថវិកា។ ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត និងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសគឺជាអាណាប័កផ្ទេរសិទ្ធិនៃថវិកា តាមរយៈដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្នុងការបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយថវិកាក្នុងវង្វង់ឥណទានថវិការបស់ខ្លួន ក្នុងលក្ខខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ។ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិទាំង

នេះ និងអង្គភាពថវិកាក្រោមឱវាទដទៃទៀត ត្រូវរៀបចំ និងអនុវត្តថវិកាឱ្យស្របតាមគោលការណ៍ និងនីតិវិធីណែនាំស្តីពីការរៀបចំ និងការអនុវត្តថវិកាកម្មវិធី។

**ប្រការ ៦.-**

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ច និងការទទួលខុសត្រូវលើការរៀបចំថវិកា ដូចខាងក្រោម÷

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិកាវិស័យសុខាភិបាល និងគម្រោងថវិកាប្រចាំឆ្នាំក្នុងវិស័យសុខាភិបាលទៅតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងត្រូវអនុលោមតាមផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល បែបបទនៃការរៀបចំផែនការសកម្មភាពសុខាភិបាល និងរចនាសម្ព័ន្ធកម្មវិធីដែលកំណត់ដោយក្រសួងសុខាភិបាល
- ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាវិស័យសុខាភិបាល ត្រូវលើកសំណើដាក់បញ្ចូលផែនការសកម្មភាពសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលរាជធានី ខេត្តសាមី
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ រួមទាំងចំណាយបន្ទុកបុគ្គលិក សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល។ គម្រោងថវិកានេះ ត្រូវបែងចែកលម្អិតទៅតាមអង្គភាពក្រោមឱវាទ និងទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុលោមតាមសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ចូលរួមជាមួយនឹងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាងការពារគម្រោងថវិកាកម្រិតជំនាញបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ តាមការអញ្ជើញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៧.-**

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ច និងការទទួលខុសត្រូវលើការអនុវត្តថវិកា ដូចខាងក្រោម÷

- ចាត់ចែងអនុវត្តផែនការសកម្មភាពការងាររបស់ខ្លួន ដែលបានអនុម័ត ក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំដែលបានវិភាជជូន
- រៀបចំគម្រោងកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស និងប្រចាំឆ្នាំ រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឱ្យបានទាន់ពេលវេលាកំណត់
- អនុវត្តតាមកម្មវិធីចំណូល ចំណាយ ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មានសិទ្ធិពេញលេញក្នុងកិច្ចប្រតិបត្តិការចំណូល ចំណាយរបស់ខ្លួន

- រៀបចំនិងអនុវត្តថវិការជ្ជទេយ្យបុរេប្រទាន ដោយត្រូវអនុវត្តនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានជាធរមាន
- ស្នើសុំគោលការណ៍ធានាចំណាយ និងស្នើសុំការទូទាត់ ដោយផ្ទាល់ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលបានការទូទាត់ដោយផ្ទាល់ពីរតនាគាររាជធានី ខេត្ត ដោយត្រូវគោរពទៅតាមក្របខណ្ឌនៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន និងស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ ដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- ស្នើសុំធ្វើចលនាឥណទាន ឬនិយ័តកម្មឥណទានថវិកា មកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីចលនាឥណទាន ឬនិយ័តកម្មឥណទានថវិកា ឆ្លងពីជំពូកមួយទៅជំពូកមួយទៀត ឬឆ្លងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀត និងក្នុងអនុគណនីដែលហាមឃាត់មួយចំនួន ត្រូវស្នើមកអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីលើកសំណើជូនអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមដានការអនុវត្តថវិកា និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ក្នុងក្របខណ្ឌថវិកាកម្មវិធី ស្របតាមគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី។

**ប្រការ ៨.-**

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត និងទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ត្រូវមានមន្ត្រីសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១. មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ

២. រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង និង/ ឬ រជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង

៣. ក្រុមលទ្ធកម្ម។

ការជ្រើសរើស និងការតែងតាំងមន្ត្រីខាងលើ ត្រូវឈរលើមូលដ្ឋានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្នែកចំណេះដឹង ជំនាញវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងបានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវតែងតាំងស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី ៣

## ការរៀបចំគម្រោងថវិកា

**ប្រការ ៩.-**

កញ្ចប់ថវិការួមទាំងចំណាយបន្ទុកបុគ្គលិក សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបានគ្រោងជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់

ពិភាក្សាភ្ជាប់គ្នាជាមួយនឹងគម្រោងថវិការបស់ក្រសួងសុខាភិបាល ក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងក្នុងក្របខណ្ឌថវិកាវិស័យសុខាភិបាល ព្រមទាំងក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យសុខាភិបាល។

ដើម្បីធានាដល់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព នៅក្នុងត្រីមាសទី ១ នៃឆ្នាំនីមួយៗ រដ្ឋបាលរាជធានី ខេត្ត ត្រូវលើកសំណើជូនក្រសួងសុខាភិបាល អំពីតម្រូវការមន្ត្រីវិជ្ជាជីវៈសុខាភិបាល និងតម្រូវការនៃការបណ្តុះបណ្តាលមន្ត្រីវិជ្ជាជីវៈសុខាភិបាលដែលកំពុងបម្រើការក្នុងមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ស្របតាមផែនការអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល, ការជ្រើសរើស និងការបែងចែកគ្រូពេទ្យ បុគ្គលិកជំនាញសុខាភិបាល, ការកំណត់និយាម ចំនួន និងមុខតំណែងវិជ្ជាជីវៈរបស់បុគ្គលិកសម្រាប់មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព រួមទាំងការផ្តល់ការបណ្តុះបណ្តាលមូលដ្ឋាន និងការបណ្តុះបណ្តាលបន្តដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។

**ប្រការ ១០.-**

ដំណើរការនៃការរៀបចំថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត និងថវិការដ្ឋបាលកណ្តាលនៃក្រសួងសុខាភិបាល ត្រូវរៀបចំរួមជាមួយគ្នាទៅតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ទាំងការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់វិស័យសុខាភិបាល និងការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលរាជធានី ខេត្ត និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាសង្គតិភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយវិស័យសុខាភិបាល។

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុករៀបចំគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងក្របខណ្ឌថវិកាកម្មវិធីក្រោមការដឹកនាំ និងការ-ណែនាំរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត រួចបញ្ជូនទៅសុំការពិនិត្យ និងឯកភាពពី គណៈអភិបាលរាជធានី ខេត្ត មុននឹងដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័ត។ បន្ទាប់ពីបានការអនុម័តពីក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណើគម្រោងថវិកានេះ ១ (មួយ) ច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យការផ្សារភ្ជាប់គម្រោងថវិកានេះ ជាមួយនឹងគម្រោងថវិការបស់ក្រសួងសុខាភិបាល និង ១ (មួយ) ច្បាប់ជូនក្រសួងសុខាភិបាលដើម្បីពិនិត្យសង្គតិភាព ស្របតាមផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល បែបបទនៃការរៀបចំផែនការសកម្មភាពសុខាភិបាល និងរចនាសម្ព័ន្ធកម្មវិធីដែលកំណត់ដោយក្រសួងសុខាភិបាល។

សំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត នឹងត្រូវដាក់ពិភាក្សាការពាររួមគ្នា ជាមួយនឹងសំណើគម្រោងថវិការដ្ឋបាលកណ្តាលនៃក្រសួងសុខាភិបាល នៅ

កម្រិតបច្ចេកទេសដែលត្រូវរៀបចំ និងដឹកនាំដោយអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យក្នុងក្របខណ្ឌថវិកាវិស័យសុខាភិបាល និងក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី ក៏ដូចជាក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ក្នុងការចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យសុខាភិបាល។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង និងអមដោយប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវចូលរួមការពារគម្រោងថវិកាតាមការអញ្ជើញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត នឹងត្រូវសម្រេចផ្តល់ជូនទៅតាមលទ្ធភាពថវិកាប្រចាំឆ្នាំ ក្នុងក្របខណ្ឌកញ្ចប់ថវិកាវិស័យសុខាភិបាលនៅក្នុងកិច្ចពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងរដ្ឋបាលរាជធានី ខេត្ត សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

**ប្រការ ១១.-**

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដែលត្រូវបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ គឺជាថវិកាឧបសម្ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត ដែលត្រូវបានរៀបចំលម្អិតជាសៀវភៅថវិកា តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ជូនទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីអនុវត្ត និងសម្រាប់ជូនទៅក្រសួងសុខាភិបាលដើម្បីតាមដានការអនុវត្តក្នុងក្របខណ្ឌវិស័យសុខាភិបាល។

បន្ថែមលើធនធានហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ដែលទទួលបានពីថវិកាថ្នាក់ជាតិ តាមលទ្ធភាពថវិកាប្រចាំឆ្នាំក្នុងក្របខណ្ឌនៃកញ្ចប់ថវិកាវិស័យសុខាភិបាល រដ្ឋបាលរាជធានី ខេត្ត អាចប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងៗទៀត ព្រមទាំងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់រដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្តល់ការគាំទ្របន្ថែមដល់ការអនុវត្តមុខងារសុខាភិបាលដែលបានប្រគល់។

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដែលត្រូវបានបែងចែកលម្អិតទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា ដូចមានចែងក្នុងសៀវភៅថវិកា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានផ្ទេរជូនរដ្ឋបាលរាជធានី ខេត្ត ដើម្បីអនុវត្តឱ្យបានទាន់ពេលវេលាចាប់ពីថ្ងៃទី ១ ខែមករា នៃឆ្នាំសារពើពន្ធនីមួយៗ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលជាអាណាប័កដើមខ្សែនៃកញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវចេញដីកាដើម្បីផ្ទេរសិទ្ធិជូនប្រធានមន្ទីរសុខាភិបាល និងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃរដ្ឋបាលរាជធានី ខេត្ត ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់អនុវត្តកញ្ចប់ថវិកានេះ។

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបែងចែកថវិកាឱ្យដល់អង្គភាពក្រោមឱវាទដទៃទៀតឱ្យបានទាន់ពេលវេលា ដើម្បីអនុវត្តនៅក្នុងឆ្នាំសារពើពន្ធនីមួយៗ។ ឥណទានថវិកាត្រូវបានវិភាជតាមចំណាត់ថ្នាក់នៃមាតិកាថវិកាស្របតាមអាទិភាព និងទំហំការងារ និងតាមស្មារតីនៃការរៀបចំថវិកា។

## ជំពូកទី ៤
## នីតិវិធីនៃការអនុវត្តថវិកា

**ប្រការ ១២.-**

ក្រោយពេលទទួលបានប្រកាសស្តីពីការបែងចែកឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានមន្ទីរសុខាភិបាល និងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលទទួលបានសិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ ពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចាប់ផ្តើមចាត់ចែងបញ្ជា និងជម្រះចំណូល និងធ្វើប្រតិបត្តិការចំណាយតាមដំណាក់កាលស្នើសុំធានាចំណាយ ធ្វើលទ្ធកម្មសាធារណៈ ជម្រះបញ្ជី និងបោះផ្សាយអាណត្តិកិច្ច ស្របតាមច្បាប់ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

**ប្រការ ១៣.-**

មិនត្រូវបានអនុញ្ញាតឱ្យអនុវត្តចំណាយលើសពីឥណទានថវិកាដែលបានបែងចែក លើកលែងតែមានតម្រូវការផ្ទេរឥណទាន ឬនិយ័តកម្ម។

ក្នុងករណីចាំបាច់ និងមានតម្រូវការជាក់ស្តែង ការធ្វើនិយ័តកម្មឥណទានថវិកាត្រូវបានអនុញ្ញាតនៅដើមត្រីមាសទី ២។ ការធ្វើនិយ័តកម្មឥណទានថវិកាត្រូវអនុលោមតាមគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីដែលមានជាធរមាន។

ដោយឡែក ការស្នើសុំធ្វើនិយ័តកម្មឥណទានថវិកាក្នុងអនុគណនីដែលហាមឃាត់មួយចំនួន និងការស្នើសុំធ្វើនិយ័តកម្មឆ្លងជំពូក ក៏ដូចជាការស្នើសុំបន្ថែមឥណទានថវិកា ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវលើកសំណើសុំការឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីលើកសំណើធ្វើនិយ័តកម្មឥណទានទាំងនេះ មកអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច។ ប្រកាសស្តីពីការធ្វើនិយ័តកម្ម ឬបន្ថែមឥណទានថវិកាត្រូវចម្លង ១ (មួយ) ច្បាប់ជូនក្រសួងសុខាភិបាល។

**ប្រការ ១៤.-**

ការបើកផ្តល់បុរេប្រទាន ជាទូទៅមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តទេនៅកម្រិតមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ។ ប៉ុន្តែសម្រាប់ការបើកផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ តាមការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវស្នើសុំមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីបន្ត

នីតិវិធីទៅរតនាគាររាជធានី ខេត្ត ធ្វើការបើកផ្ដល់។ លិខិតបុរេប្រទានត្រូវចម្លង ១ (មួយ) ច្បាប់ទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

**ប្រការ ១៥.-**

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ផ្អែកតាមគម្រោងបៀវត្ស ស្របតាមក្របខណ្ឌ និងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ ដែលត្រូវបានស្នើសុំទិដ្ឋាការពីមន្ទីរមុខងារសាធារណៈ និងផ្អែកលើតារាងបៀវត្ស ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ រួចបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្ដល់ទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ។ អាណត្តិបើកប្រាក់ដែលត្រូវបានចុះទិដ្ឋាការរួច ព្រមជាមួយនឹងលិខិតយុត្តការគាំទ្រត្រូវបញ្ជូនទៅរតនាគាររាជធានី ខេត្ត ដើម្បីពិនិត្យ និងបើកផ្ដល់។

**ប្រការ ១៦.-**

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលរបស់មន្ទីរសុខាភិបាល ទីភ្នាក់ងារប្រតិបត្តិការពិសេស និងអង្គភាពក្រោមឱវាទដទៃទៀតនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៧.-**

ចំណាយថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលរបស់មន្ទីរសុខាភិបាល ទីភ្នាក់ងារប្រតិបត្តិការពិសេស និងអង្គភាពក្រោមឱវាទដទៃទៀតនៃរដ្ឋបាលរាជធានី ខេត្ត ជាកម្មវត្ថុនៃការឆ្លងទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ ដែលបានទទួលការតែងតាំងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ១៨.-**

កិច្ចប្រតិបត្តិការចំណាយថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលរបស់មន្ទីរសុខាភិបាល និងទីភ្នាក់ងារប្រតិបត្តិការពិសេសនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័កផ្ទេរសិទ្ធិដទៃទៀតមាន ៤ ដំណាក់កាលសំខាន់ៗ÷

- ដំណាក់កាលធានាចំណាយ
- ដំណាក់កាលលទ្ធកម្មសាធារណៈ
- ដំណាក់កាលជម្រះបញ្ជី
- ដំណាក់កាលអាណត្តិកិច្ច និងទូទាត់។

**ប្រការ ១៩.-**

ចំណាយថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលរបស់មន្ទីរសុខាភិបាល និងទីភ្នាក់ងារប្រតិបត្តិការពិសេសនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវអនុវត្តទៅតាមច្បាប់ និង

បទប្បញ្ញត្តិជាធរមាន។ ចំពោះមុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មត្រូវអនុវត្តទៅតាមវិធីសាស្រ្ត និងនីតិវិធីលទ្ធកម្មសាធារណៈ ដែលបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈជាធរមាន។

**ប្រការ ២០.-**

ប្រធានមន្ទីរសុខាភិបាល និងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវទទួលខុសត្រូវលើកិច្ចជម្រះបញ្ជី។ កិច្ចជម្រះបញ្ជីអាចធ្វើទៅបានបន្ទាប់ពីការបញ្ជាទិញកិច្ចសន្យាលទ្ធកម្មទិនិញ សំណង់ ឬសេវានានាត្រូវបានបំពេញរួចរាល់។ កិច្ចជម្រះបញ្ជីធ្វើឡើងដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវពិតប្រាកដនៃការធានាចំណាយ និងត្រៀមទឹកប្រាក់ទុកសម្រាប់ទូទាត់ឱ្យមុខសញ្ញានោះ។

**ប្រការ ២១.-**

ប្រធានមន្ទីរសុខាភិបាល និងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ដោយផ្ទាល់ និងបញ្ជូនមកអភិបាលហិរញ្ញវត្ថុដើម្បីពិនិត្យ និងផ្តល់ទិដ្ឋាការ។

អាណត្តិបើកប្រាក់ ដែលគ្មានទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ គឺពុំអាចប្រើប្រាស់បានសម្រាប់ការទូទាត់ ឬដកប្រាក់ពីរតនាគាររាជធានី ខេត្ត បានឡើយ។

**ប្រការ ២២.-**

ប្រធានមន្ទីរសុខាភិបាល និងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវអនុវត្តប្រតិបត្តិការចំណូល ចំណាយ និងការរៀបចំផែនការថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅពេលដែលប្រព័ន្ធត្រូវបានដំឡើង និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទ ស្របតាមនីតិវិធីស្តង់ដារបស់ប្រព័ន្ធ។ ដោយឡែកមុនពេលដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ប្រតិបត្តិការចំណូល ចំណាយ និងការរៀបចំផែនការថវិកាត្រូវរក្សាដូចនីតិវិធីដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន តាមនីតិវិធីអនុវត្តថវិកាដែលមានចែងក្នុងប្រកាសអន្តរក្រសួងនេះ និងតាមការណែនាំបន្ថែមដោយឡែក។

**ប្រការ ២៣.-**

មន្ទីរសុខាភិបាល ទីភ្នាក់ងារប្រតិបត្តិការពិសេស និងអង្គភាពក្រោមឱវាទដទៃទៀតនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវតាមដាន កត់ត្រា និងកិច្ចបញ្ជិការចំណូល ចំណាយថវិកា ស្របតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលមានជាធរមាន។

**ប្រការ ២៤.-**

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មលើការអនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលក្នុងក្របខណ្ឌថវិកាកម្មវិធី។ របាយការណ៍សមិទ្ធកម្មលើការអនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាល ក្នុងក្របខណ្ឌថវិកាកម្មវិធីគឺជារបាយការណ៍ដែលឆ្លុះបញ្ចាំងអំពីលទ្ធផល និងវឌ្ឍនភាពនៃការអនុវត្តការងារតាមចំណាត់ថ្នាក់កម្មវិធី ដើម្បីរួមចំណែកសម្រេចគោលបំណង និងគោលនយោបាយរបស់វិស័យសុខាភិបាល។ មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវតាមដាន និងបូកសរុបការអនុវត្តថវិការបស់ខ្លួន រួមទាំងអង្គភាពក្រោមឱវាទដទៃទៀត និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាប្រចាំ និងតាមពេលវេលាកំណត់ដោយអនុលោមទៅតាមតារាងគម្រូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

របាយការណ៍ខាងលើនេះ ត្រូវដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ពិនិត្យ និងដាក់ជូនក្រុមប្រឹក្សាពិនិត្យអនុម័ត។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវរៀបចំបញ្ជូនរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ មកក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**ប្រការ ២៥.-**

ឥណទានថវិការបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ដែលអនុម័តដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ទន្ទឹមនេះ ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផលចំពោះក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រកាសអន្តរក្រសួងនេះ។

**ប្រការ ២៦.-**

ការរៀបចំថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត សម្រាប់ឆ្នាំ២០២១ ត្រូវអនុវត្តតាមប្រតិទិន នៃការរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវចាប់ផ្ដើមពីខែមីនា ឆ្នាំ២០២០។

ប្រកាសអន្តរក្រសួងស្ដីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលនេះមានប្រសិទ្ធភាពអនុវត្តពេញលេញចាប់ពីឆ្នាំ២០២១ តទៅ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៨.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ព្រមទាំងគ្រប់ក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងប្រធានមន្ទីរសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២០

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី<br>ក្រសួងមហាផ្ទៃ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | រដ្ឋមន្ត្រី<br>ក្រសួងសុខាភិបាល |
|---|---|---|
| សម្តេចក្រឡាហោម ស ខេង | អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | ម៉ម ប៊ុនហេង |

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ២៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ